ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថានឯកអគ្គរាជទូតកម្ពុជា
ប្រចាំប្រទេសជប៉ុន

# សេចក្តីថ្លែងការណ៍ចំពោះ

## របស់អ្នកនាំពាក្យនៃ ស្ថានទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសជប៉ុន

ស្ថានទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសជប៉ុន សូមបញ្ជាក់ឡើងវិញអំពីការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងនឹងការឆបោកតាមប្រព័ន្ធអនឡាញ បទល្មើសបច្ចេកវិទ្យា ការជួញដូរមនុស្ស ពលកម្មដោយបង្ខំ ការលាងលុយកខ្វក់ និងគ្រប់ទម្រង់នៃបទល្មើសឧក្រិដ្ឋកម្មឆ្លងដែនដែលមានការរៀបចំ។

រាជរដ្ឋាភិបាលកម្ពុជា បានកំណត់យ៉ាងច្បាស់ថា ការប្រយុទ្ធប្រឆាំងនឹងការឆបោកតាមប្រព័ន្ធអនឡាញ គឺជាអាទិភាពជាតិសំខាន់បំផុត ដើម្បីការពារសន្តិសុខសង្គម ការពារសុវត្ថិភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ និងជនបរទេសដែលរស់នៅក្នុងប្រទេសកម្ពុជា ព្រមទាំងថែរក្សាកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់កម្ពុជា នៅលើឆាកអន្តរជាតិ។

ការឆបោកតាមប្រព័ន្ធអនឡាញ និងអំពើឆបោកតាមបច្ចេកវិទ្យា គឺជាបទល្មើសឆ្លងដែនដ៏ស្មុគស្មាញ ដែលកំពុងប៉ះពាល់ដល់ប្រទេសជាច្រើនទូទាំងពិភពលោក។ កម្ពុជា មិនមែនជាប្រភពនៃសកម្មភាពឧក្រិដ្ឋកម្មទាំងនេះទេ ប៉ុន្តែជាប្រទេសមួយដែលកំពុងប្រឈមមុខ និងប្រយុទ្ធយ៉ាងសកម្មប្រឆាំងនឹងបណ្តាញឧក្រិដ្ឋកម្មអន្តរជាតិដែលប្រតិបត្តិការឆ្លងកាត់ព្រំដែន។

ក្រោមការដឹកនាំដោយផ្ទាល់របស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** រាជរដ្ឋាភិបាលបានអនុវត្តគោលនយោបាយមិនអត់ឱនឱ្យជាដាច់ខាត និងបានដាក់ចេញយុទ្ធនាការទូទាំងប្រទេស ដើម្បីបំបែកបណ្តាញឧក្រិដ្ឋកម្ម បំបាត់សមត្ថភាពប្រតិបត្តិការ កាត់ផ្តាច់ប្រភពហិរញ្ញវត្ថុ និងបិទបណ្តាញប្រតិបត្តិការខុសច្បាប់។

ចាប់ពីខែកក្កដា ឆ្នាំ២០២៥ ដល់ពាក់កណ្តាលខែមេសា ឆ្នាំ២០២៦ អាជ្ញាធរកម្ពុជា៖

- បានបង្ក្រាបករណីឆបោកតាមប្រព័ន្ធអនឡាញជាង ២៥០ ករណីទូទាំងប្រទេស
- បានបិទទីតាំងពាក់ព័ន្ធកាស៊ីណូចំនួន ៩១ កន្លែង ដែលជាប់ពាក់ព័ន្ធនឹងសកម្មភាពខុសច្បាប់
- បានបញ្ជូនសំណុំរឿងចំនួន ១១២ ករណីទៅតុលាការ ដែលពាក់ព័ន្ធនឹងជនសង្ស័យប្រមាណ១,០៨៩ នាក់ មានសញ្ជាតិផ្សេងៗគ្នា
- បានបណ្តេញជនបរទេសចំនួន ១៣,០៣៩ នាក់ មាន ៣៣ សញ្ជាតិ ដែលពាក់ព័ន្ធនឹងសកម្មភាពឆបោកតាមប្រព័ន្ធអនឡាញ
- បានពង្រឹងកិច្ចសហប្រតិបត្តិការលើប្រតិបត្តិការជាមួយដៃគូអន្តរជាតិ និងស្ថាប័នអនុវត្តច្បាប់។



8-6-9 AKASAKA, MINATO-KU, TOKYO 107-0052
Tel : +81 3-5412-8521 Fax: +81 3-5412-8526
Email: camemb.jpn@mfaic.gov.kh

រាជរដ្ឋាភិបាលកម្ពុជា ក៏បានពង្រឹងក្របខណ្ឌច្បាប់ និងស្ថាប័ន ដើម្បីប្រយុទ្ធប្រឆាំងនឹងបទល្មើសបច្ចេកវិទ្យា តាមរយៈ៖

- ច្បាប់ស្តីពីការប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធអនឡាញ
- សេចក្តីណែនាំស្តីពីយុទ្ធនាការលុបបំបាត់ការឆបោកតាមប្រព័ន្ធអនឡាញ
- អនុក្រឹត្យលេខ ០៣ អនក្រ.បក ស្តីពីការគ្រប់គ្រងសន្តិសុខសុវត្ថិភាពតាមទីតាំងរស់នៅប្រមូលផ្តុំ
- យន្តការអន្តរក្រសួងពាក់ព័ន្ធនឹងនីតិវិធីអនុវត្ត និងការដាក់ទណ្ឌកម្ម។

ច្បាប់ស្តីពីការប្រយុទ្ធប្រឆាំងនឹងការឆបោកតាមប្រព័ន្ធអនឡាញ បានកំណត់បទល្មើសថ្មី និងការដាក់ទណ្ឌកម្មកាន់តែតឹងរ៉ឹង ចំពោះអំពើឆបោកតាមបច្ចេកវិទ្យា មជ្ឈមណ្ឌលឆបោកតាមប្រព័ន្ធអនឡាញ ការជ្រើសរើស និងបណ្តុះបណ្តាលសម្រាប់ប្រតិបត្តិការឆបោក ការប្រមូលព័ត៌មានអត្តសញ្ញាណផ្ទាល់ខ្លួនដោយខុសច្បាប់ និងសកម្មភាពលាងលុយកខ្វក់ដែលពាក់ព័ន្ធ។ ការផ្តន្ទាទោសអាចមានទណ្ឌកម្មធ្ងន់ធ្ងរ រួមទាំងការជាប់ពន្ធនាគារអស់មួយជីវិត ពិន័យជាប្រាក់យ៉ាងច្រើន និងការរឹបអូសទ្រព្យសម្បត្តិ។

កម្ពុជា ក៏បានពង្រឹងកិច្ចសហប្រតិបត្តិការជាមួយប្រទេសដៃគូ អង្គការអន្តរជាតិ និងយន្តការពហុភាគីពាក់ព័ន្ធក្នុងការស៊ើបអង្កេត បង្ក្រាប បញ្ជូនជនសង្ស័យ ការជួយសង្គ្រោះជនរងគ្រោះ និងការផ្លាស់ប្តូរព័ត៌មាន និងជំនាញបច្ចេកទេសពាក់ព័ន្ធនឹងបណ្តាញឧក្រិដ្ឋកម្មតាមអនឡាញ។

ក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៦ **សម្តេចធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** បានសង្កត់ធ្ងន់ជាថ្មីនូវបទបញ្ជាដ៏តឹងរ៉ឹងបំផុត ដល់អាជ្ញាធរមានសមត្ថកិច្ច និងកងកម្លាំងពាក់ព័ន្ធទាំងអស់ ឱ្យបន្តពង្រឹងវិធានការអនុវត្តច្បាប់ដោយ "មិនអត់ឱន មិនបន្ធូរបន្ថយ និងគ្មានករណីលើកលែង"។

វិធានការជាក់ស្តែង និងលទ្ធផលសំខាន់ៗទាំងនេះ បានបង្ហាញយ៉ាងច្បាស់ពីការប្តេជ្ញាចិត្តដ៏ម៉ឺងម៉ាត់ ឆន្ទៈនយោបាយ និងការបន្តខិតខំរបស់កម្ពុជា ក្នុងការលុបបំបាត់ប្រតិបត្តិការឆបោកតាមប្រព័ន្ធអនឡាញ និងពង្រឹងនីតិរដ្ឋ។

ស្ថានទូតព្រះរាជាណាចក្រកម្ពុជា សូមអំពាវនាវឱ្យមានការយល់ដឹងប្រកបដោយតុល្យភាព សត្យានុម័ត និងផ្អែកលើភស្តុតាង ចំពោះកិច្ចខិតខំប្រឹងប្រែង និងសមិទ្ធផលជាក់ស្តែងរបស់កម្ពុជា ក្នុងការដោះស្រាយបញ្ហាប្រឈមជាសកលទាំងនេះ។

កម្ពុជា នៅតែបន្តប្តេជ្ញាចិត្តធ្វើការយ៉ាងជិតស្និទ្ធជាមួយជប៉ុន និងសហគមន៍អន្តរជាតិ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការប្រឆាំងនឹងបទល្មើសបច្ចេកវិទ្យា និងឧក្រិដ្ឋកម្មឆ្លងដែន ដើម្បីផលប្រយោជន៍សន្តិសុខតំបន់ និងអន្តរជាតិ។

ស្ថានទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសជប៉ុន

ថ្ងៃពុធ ១៤រោច ខែពិសាខ ឆ្នាំឧសភា អដ្ឋស័ក ព.ស.២៥៧០
តូក្យូ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៦

KINGDOM OF CAMBODIA
NATION RELIGION KING

ROYAL EMBASSY OF CAMBODIA
JAPAN

[Unofficial Translation]

## Clarification Statement

## by the Spokesperson of the Royal Embassy of Cambodia to Japan

The Royal Embassy of Cambodia to Japan reiterates the firm commitment of the Royal Government of Cambodia to combating online scams, cybercrime, human trafficking, forced labor, money laundering, and all forms of transnational organized crime.

The Royal Government of Cambodia has clearly established the fight against online scams as a top national priority in order to safeguard social security, protect the safety and well-being of citizens and foreign residents, and uphold the dignity and honor of Cambodia on the international stage.

Online scams and cyber-enabled fraud are complex transnational crimes affecting many countries worldwide. Cambodia is not the source of these criminal activities, but rather one of the countries actively confronting international criminal networks operating across borders.

Under the direct leadership of **Samdech Moha Borvor Thipadei Hun Manet, Prime Minister of the Kingdom of Cambodia**, the Royal Government has adopted a strict zero-tolerance policy and launched a comprehensive nationwide campaign to dismantle criminal networks, eliminate their operational capacity, sever financial sources, and close illegal operational channels.

From July 2025 to mid-April 2026, Cambodian authorities:

- cracked down on more than 250 online scam cases nationwide;
- closed 91 casino-related locations linked to illegal activities;
- filed 112 cases before the courts involving approximately 1,089 suspects of multiple nationalities;
- deported 13,039 foreign nationals of 33 different nationalities connected to online scam activities;
- and strengthened operational cooperation with international partners and law enforcement agencies.

The Royal Government has also reinforced the legal and institutional framework to combat technology-enabled crimes through:

- the Law on Combating Online Scams;
- the Directive on the Campaign to Eliminate Online Scams;

- Sub-Decree No. 03 ANKR.BK on the Management of Safety and Security in Concentrated Residential Areas;
- and inter-ministerial mechanisms relating to enforcement procedures and penalties.

The Law on Combating Online Scams introduces new criminal offences and stronger penalties targeting technology-based fraud, online scam centers, recruitment and training for scam operations, unlawful collection of personal identification information, and related money laundering activities. Convictions may result in severe criminal penalties, including life imprisonment, substantial fines, and asset seizure.

Cambodia has also intensified cooperation with partner countries, international organizations, and relevant multilateral mechanisms in the investigation, suppression, extradition of suspects, rescue of victims, and exchange of information and technical expertise related to online criminal networks.

During the plenary session of the Council of Ministers on 23 April 2026, **Prime Minister Samdech Thipadei Hun Manet** reiterated the strictest directive to all competent authorities and relevant forces to continue intensifying enforcement measures with no tolerance, no leniency, and no exception.

These concrete measures and significant results clearly demonstrate Cambodia's serious determination, political will, and sustained commitment to eradicating online scam operations and strengthening the rule of law.

The Royal Embassy of Cambodia respectfully calls for balanced, objective, and evidence-based understanding of Cambodia's active efforts and concrete achievements in addressing these global challenges.

Cambodia remains fully committed to working closely with Japan and the international community to strengthen cooperation against cybercrime and transnational organized crime in the interest of regional and international security.

Royal Embassy of Cambodia to Japan

Tokyo, 15 May 2026

カンボジア王国
国民、信仰、国王

在日カンボジア王国
大使館

「非公式訳（ひこうしきやく）」

# 在日カンボジア王国大使館報道官による釈明声明

在日カンボジア王国大使館は、オンライン詐欺、サイバー犯罪、人身取引、強制労働、資金洗浄及びあらゆる形態の国際組織犯罪との闘いに対するカンボジア王国政府の揺るぎないコミットメントを改めて表明いたします。

カンボジア王国政府は、社会の安全と秩序を守り、自国民及び外国人居住者の安全と福祉を保護し、国際社会におけるカンボジアの尊厳と名誉を維持するため、オンライン詐欺対策を国家の最優先課題の一つとして明確に位置付けています。

オンライン詐欺及びテクノロジーを悪用した詐欺は、世界各国に影響を及ぼしている複雑な国際犯罪です。カンボジアはこれら犯罪の発生源ではなく、むしろ国境を越えて活動する国際犯罪ネットワークに直面し、積極的に掃討を続けている一つの国であります。

**サムデック・モハ・ボルヴォル・ティパデイ・フン・マネット・カンボジア王国首相**の直接的指導の下、カンボジア王国政府は断固たる不容認政策を採用し、犯罪組織の解体、その活動能力の排除、資金源の遮断及び違法活動経路の閉鎖を目的とした包括的な掃討作戦を展開しております。

2025 年 7 月から 2026 年 4 月中旬までの間に、カンボジア当局は以下の措置を講じました。

・全国で 250 件を超えるオンライン詐欺事案を摘発
・違法活動に関与した 91 か所のカジノ関連施設を閉鎖

・複数国籍の容疑者約1,089名に関する112件を司法当局へ送致
・オンライン詐欺活動に関与した33か国13,039名の外国人を国外退去処分
・国際的パートナー及び法執行機関との協力を強化

さらに、カンボジア王国政府は、テクノロジー関連犯罪対策のため、以下を通じて法的・制度的枠組みを強化しました。

・オンライン詐欺対策法
・オンライン詐欺撲滅キャンペーン指令
・集中居住地域における安全及び治安管理に関する政令第03号（ANKR.BK）
・執行手続及び罰則に関する省庁横断的メカニズム

「オンライン詐欺対策法」は、テクノロジーを利用した詐欺、オンライン詐欺拠点、詐欺活動の勧誘及び訓練、個人識別情報の不法収集並びに関連する資金洗浄行為に対する新たな犯罪類型及び厳格な罰則を導入しています。有罪判決を受けた場合には、終身刑、多額の罰金及び資産没収を含む厳しい刑罰が科される可能性があります。

また、カンボジアは、オンライン犯罪ネットワークに関連する捜査、取締り、容疑者の引渡し、被害者救済並びに情報及び技術的専門知識の共有において、関係各国、国際機関及び関連多国間枠組みとの協力を一層強化しています。

2026年4月23日に開催された閣議において、**サムデック・ティパデイ・フン・マネット首相**は、全ての関係当局及び関係部隊に対し、「いかなる容認も、例外も、猶予も認めない」との最も厳格な方針の下で、取締りをさらに強化するよう改めて指示しました。

これらの具体的措置及び重要な成果は、オンライン詐欺撲滅及び法の支配強化に向けたカンボジアの真摯な決意、強い政治的意思及び継続的な取組を明確に示すものです。

在日カンボジア王国大使館は、これら世界規模の課題に対処するためのカンボジアの具体的な取り組みと実績に対し、証拠に基づいた、客観的かつバランスの取れた理解を呼びかけるものであります。

カンボジアは、地域および国際社会の安全保障上の利益のため、サイバー犯罪や国境を越える国際犯罪に対抗する協力を強化すべく、日本ならびに国際社会と緊密に連携していくとの決意を、引き続き堅持するものであります。

在日カンボジア王国大使館
東京、2026年5月15